**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ៦៥/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងកិច្ចប្រជុំលើកទី១៥ នៃគណៈកម្មការចម្រុះ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី

តបតាមការអញ្ជើញរបស់ **ឯកឧត្តម ថងសាវណ្ណ ភុមវិហាន** រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងបានធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំលើកទី១៥ នៃគណៈកម្មការចម្រុះ កម្ពុជា-ឡាវ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី (JCBC) នៅទីក្រុងវៀងចន្ទន៍ ចាប់ពីថ្ងៃទី២៦ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០២៥។

នៅក្នុងជំនួបសម្តែងការគួរសមដាច់ដោយឡែកចំពោះ **ឯកឧត្តម ថងលុន ស៊ីសុលីត** ប្រធានរដ្ឋ និង**ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានពាំនាំការសួរសុខទុក្ខ និងការអបអរសាទរដ៏ស្មោះរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជូនថ្នាក់ដឹកនាំឡាវក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៥០ នៃបុណ្យជាតិរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវខាងមុខនេះ។

ថ្នាក់ដឹកនាំឡាវទាំងពីរបានថ្វាយព្រះពរ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និងបានផ្តាំផ្ញើការនឹករលឹក និងសួរសុខទុក្ខជូន **សម្តេចតេជោប្រធានព្រឹទ្ធសភា** និង**សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។ ថ្នាក់ដឹកនាំឡាវ និង**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាពជាបងប្អូន និងកក់ក្តៅរវាងប្រទេសទាំងពីរហើយបានបញ្ជាក់ អំពីការធ្វើឱ្យចំណងមិត្តភាព សាមគ្គីភាព ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែងកម្ពុជា-ឡាវកាន់តែស៊ីជម្រៅ ស្របតាមស្មារតីមិត្តភាពជាប្រពៃណី និងភាពជាអ្នកជិតខាងល្អ។


អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

នៅព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ក្នុងអំឡុងពេលកិច្ចប្រជុំ JCBC លើកទី១៥ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** និង**ឯកឧត្តមរដ្ឋមន្ត្រី ថងសាវណ្ណ ភុមវិហាន** បានផ្លាស់ប្តូរព័ត៌មានស្តីពីការវិវឌ្ឍថ្មីៗនៅក្នុងប្រទេសរៀងៗខ្លួន និងពិភាក្សាយ៉ាងស៊ីជម្រៅ ក្នុងការរិះរកមធ្យោបាយ ដើម្បីធ្វើឱ្យភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែងរវាងប្រទេសទាំងពីរកាន់តែស៊ីជម្រៅ។ ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តយ៉ាងខ្លាំងចំពោះវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ក្រោយកិច្ចប្រជុំ JCBC លើកទី១៤ ព្រមទាំងបញ្ជាក់សាជាថ្មីនូវ ការប្តេជ្ញាចិត្តក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។

អំពី**កិច្ចសហប្រតិបត្តិការនយោបាយ** រដ្ឋមន្ត្រីទាំងពីរបានសង្កត់ធ្ងន់អំពីសារៈសំខាន់ នៃការផ្លាស់ប្តូរទស្សនកិច្ចជាប្រចាំ និងគ្រប់កម្រិត ដើម្បីពង្រឹងចំណងមិត្តភាព និងសាមគ្គីភាពយូរអង្វែងរវាងប្រទេសទាំងពីរ។ ភាគីទាំងពីរបានអបអរសាទរចំពោះលទ្ធផលប្រកបដោយផ្លែផ្កា នៃដំណើរទស្សនកិច្ចទៅវិញទៅមករបស់ថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរមានជាអាទិ៍ ទស្សនកិច្ចរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅប្រទេសឡាវ ក្នុងខែមីនា ឆ្នាំ២០២៤ ទស្សនកិច្ចរបស់ **ឯកឧត្តម សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រី នៃស.ប.ប.ឡាវ នៅប្រទេសកម្ពុជា ក្នុងខែធ្នូ ឆ្នាំ២០២៤ និងទស្សនកិច្ចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅប្រទេសឡាវ ក្នុងខែកុម្ភៈ ឆ្នាំ២០២៥។ រដ្ឋមន្ត្រីទាំងពីរបានឯកភាពបង្កើតយន្តការដើម្បីបង្កើនកិច្ចពិភាក្សារវាងក្រសួងការបរទេស នៃប្រទេសទាំងពីរ។

ចំពោះ **កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច** រដ្ឋមន្ត្រីទាំងពីរបានទទួលស្គាល់សក្តានុពលសំខាន់សម្រាប់ការពង្រីក ពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងឯកភាពលើកកម្ពស់ទំនាក់ទំនងរវាងធុរកិច្ច និងធុរកិច្ចឱ្យកាន់តែជិតស្និទ្ធ។ ថ្នាក់ដឹកនាំទាំងពីរក៏បានរំលឹកអំពីជោគជ័យ នៃកិច្ចប្រជុំលើកទី២ នៃគណៈកម្មាធិការពាណិជ្ជកម្មចម្រុះ (JTC) កម្ពុជា-ឡាវ ដែលបានរៀបចំនៅខែមករា ឆ្នាំ២០២៥ នៅទីក្រុងវៀងចន្ទន៍ ព្រមទាំងបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាបង្កើនការផ្លាស់ប្តូរពាណិជ្ជកម្ម និងរិះរកកិច្ចសហប្រតិបត្តិការលើវិស័យថ្មីៗទៀត។

ពាក់ព័ន្ធនឹង**បញ្ហាព្រំដែន** ភាគីទាំងពីរបានកោតសរសើរចំពោះលទ្ធផលសំខាន់ៗ នៃការកំណត់ខ័ណ្ឌសីមា និងបោះបង្គោលព្រំដែន ហើយបានសម្តែងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការជម្រុញការដោះស្រាយបញ្ហាព្រំដែន ដែលនៅសេសសល់។ ភាគីទាំងពីរបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងការកសាងព្រំដែនរួមប្រកបដោយ សន្តិភាព មិត្តភាព ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

រដ្ឋមន្ត្រីទាំងពីរបានប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យថាមពល តាមរយៈការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈ នៃការយោគយល់ ពាក់ពន្ធ័នឹងវិស័យនេះអោយកាន់តែសកម្ម។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានសម្តែងនូវអំណរគុណចំពោះមិត្តឡាវ ដែលបានផ្តល់ផ្គង់អគ្គិសនី ដើម្បីបំពេញតម្រូវការ របស់ខ្លួន។ ភាគីទាំងពីរបានពិភាក្សាគ្នាយ៉ាងស៊ីជម្រៅលើវិស័យសំខាន់ៗផ្សេងទៀត រួមមាន កសិកម្ម ការតភ្ជាប់ការដឹកជញ្ជូន ទេសចរណ៍ ការតភ្ជាប់ប្រជាជន និងប្រជាជន ព្រមទាំងវិស័យអប់រំ។

រដ្ឋមន្ត្រីទាំងពីរបានផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកលើការវិវឌ្ឍក្នុងតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍ទៅវិញទៅមក។ ថ្នាក់ដឹកនាំទាំងពីរបានបញ្ជាក់សារជាថ្មីអំពីការប្តេជ្ញាធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធលើបញ្ហាតំបន់ និងសកល ដើម្បីលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាព ព្រមទាំងបានប្តេជ្ញាបន្តគាំទ្រគ្នាទៅវិញទៅមកក្នុងវេទិកាតំបន់ និងអន្តរជាតិ។ ទន្ទឹមនឹងការបញ្ជាក់សារជាថ្មីអំពីការគាំទ្ររបស់ឡាវចំពោះកម្ពុជា **ឯកឧត្តមរដ្ឋមន្ត្រី ថងសាវណ្ណ ភុមវិហាន** បានជូនពរកម្ពុជាទទួលបានជោគជ័យធំធេងក្នុងការរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ នៅឆ្នាំ២០២៦ ខាងមុខនេះ។

កិច្ចប្រជុំបានបញ្ចប់ដោយការចុះហត្ថលេខាលើកំណត់ហេតុ នៃកិច្ចប្រជុំ JCBC លើកទី១៥ និងបានឯកភាពរៀបចំកិច្ចប្រជុំ JCBC លើកទី១៦ នៅកម្ពុជា ក្នុងឆ្នាំ២០២៧៕

ថ្ងៃសុក្រ ៨កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥